ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
បណ្ឌិត្យសភានគរបាលកម្ពុជា

លេខ : ០០២ ប.ប.ផ

# បទបញ្ជា

ដើម្បីធានាបានសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាព និងរបៀបរៀបរយ បណ្ឌិត្យសភានគរបាលកម្ពុជា ដាក់ចេញនូវបទបញ្ជា ដូចខាងក្រោម៖

១-មន្ត្រីប្រចាំការនៅប៉ុស្តិ៍ត្រួតពិនិត្យ ត្រូវពិនិត្យមើល និង/ឬត្រួតពិនិត្យឯកសាររាល់ការចេញ-ចូលក្នុងបរិវេណបណ្ឌិត្យសភានគរបាលកម្ពុជាជាប់ជាប្រចាំទាំងថ្ងៃធ្វើការ និងថ្ងៃឈប់សម្រាក។

២- ថ្នាក់ដឹកនាំ មន្ត្រី និស្សិត សិក្ខាកាម និងសិស្សនៃបណ្ឌិត្យសភានគរបាលកម្ពុជាទាំងអស់ ត្រូវស្លៀកពាក់ឯកសណ្ឋាន និងកាត់សក់ឱ្យបានត្រឹមត្រូវតាមគោលការណ៍កំណត់ និងត្រូវបង្ហាញបណ្ណសម្គាល់ខ្លួនក្នុងករណីមានការស្នើសុំពីមន្ត្រីប្រចាំការនៅប៉ុស្តិ៍ត្រួតពិនិត្យ។

៣-រថយន្ត និងទោចក្រយានយន្តគ្រប់ប្រភេទ ត្រូវមានស្លាកចេញ-ចូលបណ្ឌិត្យសភានគរបាលកម្ពុជា និងត្រូវបើកបរក្នុងល្បឿនខ្ពស់បំផុតត្រឹម ១០គីឡូម៉ែត្រក្នុងមួយម៉ោង។

៤- ទោចក្រយានយន្ត និងទោចក្រយានដែលឆ្លងកាត់ប៉ុស្តិ៍ត្រួតពិនិត្យ ត្រូវចុះបណ្តើរក្នុងចម្ងាយដែលបានកំណត់។

៥- ត្រូវចតយានជំនិះគ្រប់ប្រភេទនៅតាមទីតាំងដែលបណ្ឌិត្យសភានគរបាលកម្ពុជាបានកំណត់។

៦- មិនត្រូវប្រើប្រាស់ ឬចែកចាយគ្រឿងញៀន សេពគ្រឿងស្រវឹង និងប្រព្រឹត្តសកម្មភាពខុសច្បាប់ អំពើអសីលធម៌ និងអំពើអនាចារផ្សេងៗ។

៧- មិនត្រូវយកអាវុធ ឬគ្រឿងផ្ទុះចូលក្នុងបរិវេណបណ្ឌិត្យសភានគរបាលកម្ពុជាដោយគ្មានការអនុញ្ញាត។

៨- ភ្ញៀវដែលមកទំនាក់ទំនងជាមួយបណ្ឌិត្យសភានគរបាលកម្ពុជា ឬមកជួបនិស្សិត សិក្ខាកាម សិស្សត្រូវបង្ហាញលិខិតស្នាម និងបំពេញបែបបទនៅប៉ុស្តិ៍ត្រួតពិនិត្យ។ ករណីមានអាវុធ ឬគ្រឿងផ្ទុះត្រូវផ្ញើទុកនៅប៉ុស្តិ៍ត្រួតពិនិត្យ។

៩- អ្នកបម្រើការងារសំណង់ ឬអាហារដ្ឋាន ឬអ្នកចេញ-ចូលបណ្ឌិត្យសភានគរបាលកម្ពុជាផ្សេងទៀតត្រូវពាក់បណ្ណសម្គាល់។

១០-ថ្នាក់ដឹកនាំ មន្ត្រី និស្សិត សិក្ខាកាម សិស្ស និងអ្នកពាក់ព័ន្ធត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពនូវរាល់បទប្បញ្ញត្តិនានាដែលកំណត់ដោយបណ្ឌិត្យសភានគរបាលកម្ពុជាក្នុងស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃសុក្រ ១៣កើត ខែភទ្របទ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ជីតផ្លូ ថ្ងៃទី ៥ ខែកញ្ញា ឆ្នាំ២០២៥

**ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា**

នាយឧត្តមសេនីយ៍ សាស្ត្រាចារ្យ **ឯក មនោសែន**